# *ការតំណាង

ធ្វើបទបង្ហាញដោយ ៖

លោកស្រីមេធាវី មាស ស៊ីថន

លោកមេធាវី នង មានន្ទ

. និយមន័យ

ការតំណាង គឺជាទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យា ត្រូវមានចំពោះម្ចាស់ សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង ។ (មាត្រា ៣៦៤ ក.រ)

. គោលបំណង និងអត្ថប្រយោជន៍

- ពង្រីកស័យភាពរបស់ឯកជន
- ពង្រីកសកម្មភាពរបស់ម្ចាស់សិទ្ធិ
- បង្កើនសមត្ថភាព និងជំនាញរបស់ម្ចាស់សិទ្ធិ
- ធានាស្ថេរភាពនៃសកម្មភាពម្ចាស់សិទ្ធិ ក្នុងករណីមិនអាចធ្វើសកម្មភាពបានដោយមូលហេតុណាមួយជាយថាហេតុ
- ធានាការអនុវត្តសិទ្ធិ និងផលប្រយោជន៍របស់អសមត្ថជន
- អនុវត្តសកម្មភាពរបស់នីតិបុគ្គល

- អានុភាព និងលក្ខខណ្ឌនៃការតំណាង

ក. អានុភាព

សកម្មភាពរបស់អ្នកតំណាង ត្រូវមានអានុភាពចំពោះម្ចាស់សិទ្ធិផ្ទាល់




ខ. លក្ខខណ្ឌ

១. ម្ចាស់សិទ្ធិបានផ្ដល់សិទ្ធិអោយអ្នកតំណាងពាក់ព័ន្ធ និង សកម្មភាពតំណាង ។ អ្នកតំណាងត្រូវធ្វើសកម្មភាព ឬអនុវត្តនូវសិទ្ធិតំណាងរបស់ខ្លួន ក្នុងដែលកំណត់នៃការតំណាងដែលបានកំណត់ក្នុងកិច្ចសន្យា ។

២. កិច្ចសន្យាត្រូវបានបង្កើតរវាងអ្នកតំណាង និងតតិយជន

៣. អ្នកតំណាងបានបង្ហាញឆន្ទៈក្នុងការធ្វើសកម្មភាពសម្រាប់ម្ចាស់សិទ្ធិ ។

.ប្រភព

-សិទ្ធិតំណាងកើតដោយច្បាប់ ៖

. របបអាណាព្យាបាលទូទៅ

. របបអំណាចមេបា

. របបអាណាព្យាបាលសម្រាប់អនីតិជន

. អាពាហ៍ពិពាហ៍ (មាត្រា ៩៧៥ ក.រ)

- សិទ្ធិតំណាងកើតដោយការព្រមព្រៀង

សិទ្ធិតំណាងអាចកើតឡើងដោយការព្រមព្រៀងគ្នារវាងម្ចាស់សិទ្ធិ និងអ្នកតំណាង ។

វិសាលភាពនៃសិទ្ធិតំណាង

ក. ទំហំនៃសិទ្ធិតំណាង

ទំហំនៃសិទ្ធិតំណាង ត្រូវអាស្រ័យតាមការកកើតនៃសិទ្ធិតំណាង ។

ខ. ការកម្រិតសិទ្ធិតំណាង

ទោះបីជាមានការព្រមពព្រៀងផ្តល់អោយអ្នកតំណាងធ្វើសកម្មភាពជាច្រើនយ៉ាងណាក៏ដោយ ក៏សកម្មភាពមួយចំនួនច្បាប់បានកម្រិតជាមុនថាអ្នកតំណាងមិនអាចធ្វើសកម្មភាពនោះក្នុងនាមជាអ្នកតំណាងបានទេ ។ ពោលគឺសកម្មភាពដែលនាំអោយមានភាពផ្ទុយគ្នារវាងផលប្រយោជន៍ម្ចាស់សិទ្ធិ និងអ្នកតំណាង នោះអ្នកតំណាងមិនអាចធ្វើសកម្មភាពនោះបានទេ លើកលែងតែមានការយល់ព្រមពីម្ចាស់សិទ្ធិ ។

ការរលត់សិទ្ធិតំណាង

ការតំណាងដោយការព្រមព្រៀង ត្រូវរលត់ដោយមូលហេតុ ៖

មរណភាព ធនក្ស័យ ឬការរំលាយរបស់ម្ចាស់សិទ្ធិ

មរណភាព ធនក្ស័យ ឬការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង ។

ការបញ្ចប់អាណត្តិកិច្ចសន្យាការងារ ឬទំនាក់ទំនងគតិយុត្តផ្សេងទៀតដែលបានប្រគល់សិទ្ធិតំណាង ។

ការតំណាងដោយគ្មានសិទ្ធិ

មាន ៤ ទម្រង់៖

១. ម្ចាស់សិទ្ធិមិនដែលផ្ដល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព

២. ម្ចាស់សិទ្ធិបានផ្ដល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព ប៉ុន្តែអ្នកធ្វើសកម្មភាព បានធ្វើសកម្មភាពក្រោយសិទ្ធិតំណាងត្រូវបានបញ្ចប់ ។

៣. ម្ចាស់សិទ្ធិបានផ្ដល់សិទ្ធិតំណាងដល់អ្នកធ្វើសកម្មភាព ប៉ុន្តែអ្នកធ្វើសកម្មភាព ហួសពីទំហំនៃទំហំសិទ្ធិតំណាង ។

៤. ម្ចាស់សិទ្ធិបានផ្ដល់សិទ្ធិតំណាងប៉ុន្តែសកម្មភាពនោះក្នុងការកម្រិតសិទ្ធិតំណាង។

អានុភាពនៃការតំណាងដោយគ្មានសិទ្ធិ

អំពើដែលអ្នកតំណាងដោយគ្មានសិទ្ធិតំណាង បានធ្វើក្នុងនាមជាអ្នកតំណាងរបស់អ្នកដទៃ មិនត្រូវបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិឡើយ ។(៣៦៩-១-១)

ប៉ុន្តែបើម្ចាស់សិទ្ធិបានផ្ដល់សច្ចានុមតិនោះអានុភាពនៃកិច្ចសន្យានឹងមានដល់ម្ចាស់សិទ្ធិ

☛ប៉ុន្តែ ប្រសិនបើយើងទុកសិទ្ធិអោយម្ចាស់សិទ្ធិជាអ្នកសម្រេចថាផ្ដល់សច្ចានុមតិ ឬ មិនផ្ដល់សច្ចានុមតិនោះ តើថាអាចនិងមានផលប៉ះពាល់អ្វីខ្លះដល់ភាគីម្ខាងទៀតនៃកិច្ចសន្យា ?

## ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ក្នុងករណីដែលអ្នកតំណាងធ្វើសកម្មភាពសម្រាប់អ្នកដទៃ ហើយខ្លួនមិនអាចបញ្ជាក់អំពីសិទ្ធិតំណាង ឬ មិនអាចទទួលសច្ចានុមតិពីសាមីខ្លួនបានទេ អ្នកតំណាដោយគ្មានសិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬទទួលខុសត្រូវក្នុងការសងសំណងការខូចខាត តាមរយៈការជ្រើសរើសរបស់ភាគីម្ខាងទៀត ។

១. ក្នុងករណីភាគីម្ខាងទៀតបានដឹងអំពីអត្ថិពនៃសិទ្ធិតំណាង អ្នកតំណាងដែលគ្មានសិទ្ធអាចរួចផុតពីការទទួលខុសត្រូវ។

២. អ្នកតំណាងដែលគ្មានសិទ្ធិគ្មានកំហុស ក្នុងការធ្វើសកម្មភាពតំណាង ក៏អាចរួចផុតពីការទទួលខុសត្រូវបានដែរ ទោះបីភាគីម្ខាងទៀតមិនបានដឹងពីនត្ថិភាពនៃសិទ្ធិតំណាង ដោយកំហុសក៏ដោយ ។

ការតំណាងដែលមានលក្ខណៈជារូបភាព

**ក. ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសពីទំហំនៃសិទ្ធិតំណាង**

ឧ. លោក A បានប្រគល់សិទ្ធិតំណាង និងប្លង់ផ្ទះអោយលោក B ដើម្បីបង្កើតកិច្ចសន្យា ហ៊ីប៉ូតែក អោយខ្លួន ប៉ុន្តែក្រោយពីបានប្លង់ផ្ទះពី A ហើយលោក B បានបង្កើតកិច្ចសន្យាទិញលក់ជាមួយ C ក្នុងនាង A ។ សកម្មភាពរបស់ B បានធ្វើអោយ C ជឿជាក់ថា B ជាអ្នកតំណាងអោយម្ចាស់ផ្ទះ ហើយទទួលនូវសិទ្ធិតំណាងក្នុងការបង្កើតកិច្ចសន្យាលក់ផ្ទះនេះពិប្រាកដមែន។ ហេតុនេះ C អាចទាមទារអោយ A ដែលជាម្ចាស់ផ្ទះអនុវត្តកិច្ចសន្យា ទិញលក់ជាមួយខ្លួនបាន ។

**ខ. ការតំណាងដែលមានលក្ខណៈជារូបភាពក្រោយការរលត់សិទ្ធិតំណាង**

ឧ. លោក ក ជាបុគ្គលិកផ្នែកទីផ្សាររបស់ក្រុមហ៊ុន ខ ជាធម្មតា ក តែងតែធ្វើការ បញ្ជាទិញទំនិញពីក្រុមហ៊ុន គ តំណាងអោយ ខ ។ ថ្ងៃមួយ ក បានបញ្ជាទិញទំនិញពីក្រុមហ៊ុន គ ប៉ុន្តែក្រោយបន្តិចមកស្រាប់តែឮតំណឹងថា ក ត្រូវបានបញ្ឈប់ពីការងារ ។

** គ. ការតំណាងដែលមានលក្ខណៈជារូបភាពដោយសារការបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាង**

ឧ. A ជាម្ចាស់កម្មសិទ្ធិឯកបុគ្គល និងជានាយកតំណាងរបស់ក្រុមហ៊ុនA B ជាបងប្រុសច្បងរបស់ A ហើយបានកំពុងធ្វើការអោយ A ។ B មិនមានសិទ្ធិតំណាងដើម្បីតំណាងអោយ A ទេ ប៉ុន្តែ B តែងតែប្រើប្រាស់នាមប័ណ្ណមុខជំនួញដោយនិយាយថា ជានាយកតំណាងរបស់ A ដើម្បីទទួលបានការជឿជាក់ A បានដឹងរឿងនេះ ប៉ុន្តែមិនបានតវ៉ានោះទេ ។ B ក្នុងនាមជាអ្នកតំណាងរបស់A បានបង្កើតកិច្ចសន្យាលក់ទិញជាមួយ X ដើម្បីទិញរថយន្តដែលមានតម្លៃថ្លៃមួយគ្រឿងសម្រាបប្រើប្រាស់ក្នុងមុខជំនួញ ។

**ករណីទី០១ ៖**

A ជាម្ចាស់នៃបារមួយកន្លែង។ B ជាបុគ្គលិករបស់ A។ A បានផ្តល់សិទ្ធិតំណាងឲ្យ B ជាមួយនឹងទំហំដែល B អាចទិញស្រាណាមួយ ក្នុងចំនួនថវិកា ៣000 ដុល្លារ ក្នុងមួយខែ។ X ជាហាងលក់ស្រាមួយដែលលក់ស្រាល្អជាងគេ។ B ក្នុងនាមជាអ្នកតំណាងឲ្យ A បានទិញស្រាវីស្គីដែលមានតម្លៃថ្លៃជាងគេក្នុងតម្លៃ ៥00 ដុល្លារ ពីX ដោយមានឆន្ទៈផឹកខ្លួនឯង។ នៅពេល X បានផ្ញើវិក្ក័យបត្រចំនួន ៥00 ដុល្លារទៅ A ។ A បានបដិសេធក្នុងការបង់ប្រាក់ ដោយសារ B បានផឹកស្រាវីស្គីនោះដោយខ្លួនឯង។

**ករណីទី០២ ៖**

A ជាប្តី ហើយ B ជាប្រពន្ធ។

B បានទិញសម្លៀកបំពាក់ជាច្រើនពី C។ B បានផ្តល់សម្លៀកបំពាក់នោះជា កាដូទៅ X ដែលជាមិត្តប្រុសរបស់ B។ C បានទាមទារឲ្យ A បង់ប្រាក់ថ្លៃទិញ ដោយផ្អែកតាមមាត្រា ៩៧៥ ចំនុច ក នៃក.រ ប៉ុន្តែ A បានបដិសេធ ដោយសារ ការទិញ B មិនមែនជាសោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តី ប្រពន្ធនោះទេ។

# សូមអរគុណ ចំពោះការចូលរួម និងផ្តល់ជាមតិយោបល់